**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

## សាររំលែកមរណទុក្ខ

**គោរពជូន**

**នាយឧត្តមសេនីយ៍ មៀច សុផាន់ណា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ព្រមទាំងក្រុមគ្រួសារ**
**ចំពោះមរណភាពរបស់ ឧបាសិកា តាំង លាងហួរ**

**ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឧបាសិកា តាំង លាងហួរ** ជាម្តាយបង្កើតរបស់ឯកឧត្តម បានទទួលមរណភាព នៅថ្ងៃសុក្រ ១៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៧:០០នាទីព្រឹក ក្នុងជន្មាយុ៨៥ឆ្នាំ ដោយជរាពាធ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឧបាសិកា តាំង លាងហួរ** ជាម្តាយ ជាម្តាយក្មេក និងជាជីដូនប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** និងសូមសម្តែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធរបស់ **ឧបាសិកា តាំង លាងហួរ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ សុក្រ ១៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh